**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# ញត្តិគាំទ្រ
# របស់
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតឈ្លាសវៃដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយកំណត់អោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានសញ្ជាតិខ្មែរតែមួយគត់។ គំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតឈ្លាសវៃនេះ បានបញ្ជាក់ឱ្យឃើញពីទឹកចិត្តជាតិនិយមយ៉ាងប្តូរផ្តាច់ និងស្នេហាជាតិមាតុភូមិយ៉ាងមោះមុតគ្មានពីរ របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមគោរព និងកោតសរសើរដោយស្មោះអស់ពីដួងចិត្តយ៉ាងក្រៃលែង។ យើងខ្ញុំទាំងអស់គ្នាពិតជាមានមោទនភាពណាស់ដែលមានមេដឹកនាំដ៏ឈ្លាសវៃមួយរូបប្រកបព្រហ្មវិហារធម៌ និងស្មារតីការទទួលខុសត្រូវខ្ពស់ ចំពោះជោគវាសនារបស់ប្រទេសជាតិ និងសុខុមាលភាពប្រជាជន។

យើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមលើកដៃប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោក សូមជួយតាមបីបាច់ថែរក្សា **សម្តេចតេជោនាយករដ្ឋមន្ត្រី** សូមប្រកបតែសុខភាពល្អ សុភមង្គល និងទទួលបានជ័យជំនះថ្មីៗថែមទៀតនៅក្នុងភារកិច្ចដ៏ឧត្តុងឧត្តមដឹកនាំប្រទេសជាតិឱ្យកាន់តែរីកចម្រើនត្រចះត្រចង់ថែមទៀតនាពេលអនាគត។

ថ្ងៃពុធ ១៥រោច ខែកទ្រឹបទ ឆ្នាំឆ្លូវ ត្រីស័ក ព ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២១

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh